ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ ៣៩០៧/៣០ កសក.សល

ថ្ងៃចន្ទ ៥កើត ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៣

## ជម្រាបមក

## លោកប្រធានក្រុមហ៊ុន សុខ គង់ អាហារីណា នីហារីណា

**កម្មវត្ថុ** ៖ ការចុះកិច្ចសន្យាស្ដីពីការផ្គត់ផ្គង់ប្រេងឥន្ធនៈប្រើប្រាស់ប្រចាំឆ្នាំ២០២៣ របស់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**យោង** ៖ លិខិតលេខ ៣១៣១/២៤ កសក-អល ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០២៣ ស្ដីពីការសម្រេចជ្រើសរើស និងប្រគល់កិច្ចសន្យាស្ដីពីការផ្គត់ផ្គង់ប្រេងឥន្ធនៈប្រើប្រាស់ប្រចាំឆ្នាំ២០២៣ របស់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ សូម **លោកប្រធាន** អញ្ជើញមកចុះកិច្ចសន្យាស្ដីពីការផ្គត់ផ្គង់ប្រេងឥន្ធនៈប្រើប្រាស់ប្រចាំឆ្នាំ២០២៣ របស់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅអង្គភាពលទ្ធកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងរយៈពេល០៧ថ្ងៃ (ប្រាំពីរថ្ងៃ) យ៉ាងយូរបន្ទាប់ពីបានទទួលលិខិតនេះ ដោយភ្ជាប់មកជាមួយនូវលិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា ចេញដោយអគ្គនាយកដ្ឋានរតនាគារជាតិ ឬធនាគារពាណិជ្ជណាមួយដែលបានចុះអនុស្សរណៈយោគយល់គ្នាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដូចបានបង្ហាញជូនក្នុងឯកសារដេញថ្លៃ ដែលមានតម្លៃទឹកប្រាក់ស្មើនឹង១០%(ដប់ភាគរយ) នៃតម្លៃកិច្ចសន្យា។

អាស្រ័យហេតុនេះ សូម **លោកប្រធាន** ចាត់ចែងតាមខ្លឹមសារខាងលើតាមការគួរ។

សូម លោកប្រធាន ទទួលនូវការរាប់អានពីខ្ញុំ។

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**ឌិត ទីណា**

**ចម្លងជូន៖**

-នាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ

"ដើម្បីជ្រាប"

-ឯកសារ កាលប្បវត្តិ